# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គម្រូពាក្យបណ្ដឹងសម្រាប់ករណីសិក្សាទី១

## ពាក្យបណ្ដឹង

**ដើមចោទ** ៖ ឈ្មោះ X អាយុ ៥០ ឆ្នាំ មុខរបរពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៥៦៦៨៨៥ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០២ ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "ដើមចោទ" ៖ ខ្ញុំ P ជាមេធាវីនៃក្រុមហ៊ុនមេធាវី......................... ដែលមានអាសយដ្ឋានស្ថិតនៅ...............មហាវិថី............... សង្កាត់.............. ខណ្ឌ......... រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ............។

ទីកន្លែងបញ្ជូន ៖ ក្រុមហ៊ុនមេធាវី.................[1]

**ចុងចម្លើយ** ៖ ឈ្មោះ Y អាយុ ៦០ ឆ្នាំ មុខរបរពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៥៦៦៨៨៦ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១៥ ផ្លូវលេខ ៣៨៥ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

### សូមគោរពចូលមក
### ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ[2]

### ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ[3] ៖

(១) ចុងចម្លើយ "Y" ត្រូវធ្វើនីតិវិធីលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិដី B ទាំងមូលដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០០១០ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១០ មានទំហំ ៦០០ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ១ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ រវាង X និង Y ដោយមូលហេតុរំលាយកិច្ចសន្យាលក់-ទិញ ចុះថ្ងៃទី

---

[1]មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ទោះបីជាមិនដាក់ពីកន្លែងដែលត្រូវបញ្ជូនក៏ដោយ ក៏ជាទូទៅគឺត្រូវធ្វើការបញ្ជូនទៅការិយាល័យមេធាវីនៃបណ្ដឹង។ ប៉ុន្តែ ដើម្បីឲ្យមានភាពច្បាស់លាស់ពីទីកន្លែងដែលត្រូវបញ្ជូន វាជាការល្អដែលដាក់ពីទីកន្លែងដែលត្រូវបញ្ជូន។ ជាពិសេស ក្នុងករណីដែលមានមេធាវីច្រើនធ្វើជាអ្នកតំណាងរបស់ដើមចោទ នោះដើម្បីឲ្យមានភាពច្បាស់លាស់ក្នុងការបញ្ជូនទៅការិយាល័យមេធាវីណាមួយ នោះត្រូវដាក់ពីទីកន្លែងដែលត្រូវបញ្ជូន។

[2] ការដាក់ពាក្យបណ្ដឹងត្រូវធ្វើទៅតុលាការដែលមានសមត្ថកិច្ច (សមត្ថកិច្ចសាលាជម្រះក្ដី) (មាត្រា ០៨ មាត្រា ០៩ ជាអាទិ៍នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ រឿងក្ដីនេះ លំនៅឋានរបស់ចុងចម្លើយស្ថិតនៅខេត្តកណ្ដាល ដូច្នេះ តុលាការដែលមានសមត្ថកិច្ច គឺសាលាដំបូងខេត្តកណ្ដាល ( ក្រមនីតិវិធិរដ្ឋប្បវេណីមាត្រា ៨ ចំណុច ក)។ ម្យ៉ាងទៀត ដោយសារតែ ទីតាំងនៃអចលនវត្ថុដែលជាកម្មវត្ថុនៃបណ្ដឹងស្ថិតនៅ ភ្នំពេញ ដូច្នេះ សាលាដំបូងរាជធានីភ្នំពេញក៏មានសមត្ថកិច្ចតុលាការដែរ ( ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៩ ចំណុច ឆ និង ជ)។

[3] ខ្លឹមសារនៃសាលក្រមគឺមានភាពចាំបាច់ដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង (មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

០១ ខែឧសភា ឆ្នាំ ២០១៧[4] មកឲ្យដើមចោទ"X" ដោយដើមចោទ ត្រូវប្រគល់ប្រាក់ចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ឲ្យចុងចម្លើយ ដោយមូលហេតុរំលាយកិច្ចសន្យាលក់ទិញ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៧

**(២)** បង្គាប់ឲ្យចុងចម្លើយប្រគល់ដីដែលមានអត្តសញ្ញាណខាងលើមកឲ្យដើមចោទ

**(៣)** ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ[5]

**(៤)** ប្រកាសអនុវត្តជាបណ្តោះអាសន្ន[6]

## ១.អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ[7]

**១.** ដើមចោទ X និង ចុងចម្លើយ Y បានបង្កើតកិច្ចសន្យាលក់ទិញ ដី (លេខក្បាលដី ទីតាំង) (ខាងក្រោមនេះ ហៅថា "ដីនៃរឿងក្តី") នៅថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ២០១៧ ក្នុងតម្លៃ ១០០.០០០ (ប្រាំបីម៉ឺន)ដុល្លារអាមេរិក (រឿងក្តីនៃកិច្ចសន្យាលក់ទិញ)។ (ភស្តុតាង ១ និងភស្តុតាង ២)

**២.** ដើមចោទ X និង ចុងចម្លើយ Y បានបង្កើតកិច្ចសន្យាលក់ផ្តាច់ (Definitive Sale Letter ) ចំពោះរឿងក្តីនៃកិច្ចសន្យាលក់ទិញនេះ នៅថ្ងៃដដែលនោះ[8]។ (ភស្តុតាង ៣)

**៣.** ដើមចោទ X បានបង់ប្រាក់ ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក នៃរឿងក្តីនៃកិច្ចសន្យាលក់ទិញទៅឲ្យចុងចម្លើយ Y នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៧។ ( ភស្តុតាង ៤)

**៤.** ក្នុងកិច្ចសន្យាបានកំណត់ថានៅពេលកម្មសិទ្ធិនៃដីត្រូវបានផ្ទេរ ហើយអ្នកលក់បាន

---

[4] ការដាក់ពាក្យសុំផ្ទេរកម្មសិទ្ធិត្រូវធ្វើឡើងរួមគ្នារវាងអ្នកមានករណីយកិច្ចចុះបញ្ជីនិងអ្នកមានសិទ្ធិទាមទារឲ្យចុះបញ្ជី ប៉ុន្តែក្នុងករណីមានសេចក្តីសម្រេចរបស់តុលាការដែលចូលជាស្ថាពរ ភាគីតែម្ខាងអាចដាក់ពាក្យសុំបាន (មាត្រា ១០ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។ ចុងចម្លើយមិនមែនជាអ្នកចុះបញ្ជីនោះទេ គឺមន្ត្រីសុរិយោដីជាអ្នកចុះបញ្ជី ហេតុនេះប្រសិនបើចុងចម្លើយចាញ់ក្តី ត្រូវបានចាត់ទុកថាបានបង្ហាញឆន្ទៈ ហើយការទាមទារបែបបនេះអាចអនុវត្តបានលុះត្រាតែសេចក្តីសម្រេចរបស់តុលាការចូលជាស្ថាពរ មានន័យថា មិនអាចប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នបានឡើយ (CCP#៥២៩)។

[5] តុលាការត្រូវសម្រេចអំពីប្រាក់ប្រដាប់ក្តី (CCP#១៨២-៣) ហើយប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកចាញ់ក្តី (CCP#៦៤-១)

[6] ចំពោះចំណុចទី១នៃការទាមទារក្នុងសាលក្រមគឺមិនអាចទាមទារឲ្យប្រកាសអនុវត្តជាបណ្តោះអាសន្ននោះទេ ប៉ុន្តែចំណុចទី ២ និងទី៣ អាចទាមទារឲ្យប្រកាសអនុវត្តបណ្តោះអាសន្នបាន (មាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

[7] អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ" គឺជាចំណុចចាំបាច់ដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹង (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ)។ " អង្គហេតុដែលជាមូលហេតុនៃការទាមទារ" គឺជាចំណុចមិនបង្ខំឲ្យសរសេរនៅក្នុងពាក្យបណ្តឹងទេ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៥ កថាខណ្ឌទី៣) ប៉ុន្តែ ដើម្បីប្រាប់អំពីខ្លឹមសារនៃរឿងក្តីទៅតុលាការគប្បីសរសេរ។ ប្រសិនបើ សរសេររួមបញ្ចូលគ្នានូវចំណុចទាំងពីរនេះទៅក្នុងផ្នែកតែមួយ វានឹងមានភាពងាយស្រួល ដើម្បីឲ្យមានន័យគ្រប់គ្រាន់។

[8] " ចំពោះកិច្ចសន្យាលក់ទិញអចលនវត្ថុ ក្នុងករណីបើមិនបង្កើតជាលិខិតយថាភូតទេ កិច្ចសន្យាលក់ទិញនោះនឹងត្រូវមោឃភាព (ក្រមរដ្ឋប្បវេណី មាត្រា ៣៣៦ កថាខណ្ឌទី ២)។ ខ្លឹមសារនៃលិខិតយថាភូត មានសរសេរនៅក្នុង មាត្រា ៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ រឿងក្តីនេះ លិខិតលក់ផ្តាច់គឺជា "លិខិតដែល មន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី" ដូច្នេះ វាជាលិខិតយថាភូត។

ប្រគល់ដីឲ្យអ្នកទិញ (ចុងចម្លើយ Y) ចុងចម្លើយត្រូវប្រគល់ប្រាក់ ប៉ុន្តែចុងចម្លើយមិនប្រគល់ប្រាក់ដែលជាតម្លៃតបនៃការលក់-ទិញដីនៃរឿងក្តីនេះ ទៅដើមចោទ X។

**៥.** ប៉ុន្តែទោះបីជានៅក្រោយពេលដែលបានប្រគល់ និងផ្ទេរកម្មសិទ្ធិនៃដីនៃរឿងក្តីនេះហើយក៏ដោយ ក៏ចុងចម្លើយ Y នៅតែមិនប្រគល់ប្រាក់ដែលនៅសល់ឲ្យមកដើមចោទ។ បន្ទាប់មកដើមចោទ ក៏បានដាស់តឿនឲ្យចុងចម្លើយអនុវត្តការបង់ប្រាក់ ដោយបានកំណត់អំឡុងពេលឲ្យបង់ ប៉ុន្តែចុងចម្លើយនៅតែមិនបង់ ហេតុនេះ ដើមចោទបានបង្ហាញឆន្ទៈរំលាយកិច្ចសន្យា និងទាមទារឲ្យប្រគល់ដី និងផ្ទេរកម្មសិទ្ធិ ប៉ុន្តែចុងចម្លើយនៅតែមិនអនុវត្ត ហេតុនេះដើមចោទ ត្រូវប្តឹងទាមទារឲ្យអនុវត្តដោយបង្ខំតាមផ្លូវតុលាការ។

**៦.** ហេតុនេះដើមចោទទាមទារឲ្យចុងចម្លើយប្រគល់ដី និង ផ្ទះ (L) ព្រមទាំងធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ដោយផ្អែកតាមសិទ្ធិទាមទារឲ្យធ្វើបដិទានឡើងវិញតាមការរំលាយកិច្ចសន្យា។

## គ-ភស្តុតាង

**១.** ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅគោលបញ្ជីអចលនវត្ថុ (លិខិបញ្ជាក់ព័ត៌មានសុរិយោដី)

**២.** កិច្ចសន្យាលក់ទិញ

**៣.** លិខិតលក់ផ្តាច់

**៤.** លិខិតប្រគល់-ទទួលប្រាក់

**៥.** លិខិតជូនដំណឹង (ការដាស់តឿន)

**៦.**លិខិតជូនដំណឹង (ការរំលាយកិច្ចសន្យា)

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៧

**អ្នកតំណាងដោយអាណត្តិ**

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-លិខិតបញ្ជាក់អះអាងអំពីតម្លៃដី "ចំនួន ០២ ច្បាប់"

P

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ



## ឯកសារចម្លើយ[9]

**ដើមចោទ** ៖ ឈ្មោះ X អាយុ ៥០ ឆ្នាំ មុខរបររពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៨៦៦៨៨៨ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០២ ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "ដើមចោទ" ៖ ខ្ញុំ P ជាមេធាវីនៃក្រុមហ៊ុនមេធាវី............... ដែលមានអាសយដ្ឋានស្ថិតនៅ................ មហាវិថី.............. សង្កាត់............... ខណ្ឌ............. រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ..................។

ទីកន្លែងបញ្ជូន ៖ ក្រុមហ៊ុនមេធាវី...................

**ចុងចម្លើយ** ៖ ឈ្មោះ Y អាយុ ៦០ ឆ្នាំ មុខរបររពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៨៦៦៨៨៦ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១៤ ផ្លូវលេខ ៣៨៤ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

**អ្នកតំណាងដោយអាណត្តិ** "ចុងចម្លើយ" ៖ នាងខ្ញុំ B ជាមេធាវីនៃការិយាល័យមេធាវី.............. ដែលមានអាសយដ្ឋានស្ថិតនៅ................ សង្កាត់................ ខណ្ឌ................. រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ..............................។

ទីកន្លែងបញ្ជូន ៖ ការិយាល័យមេធាវី....................

## <u>សូមគោរពចូលមក</u>
## លោក W ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**<u>កម្មវត្ថុ</u>**៖សុំដាក់**ឯកសារចម្លើយដើម្បីឆ្លើយតប**នឹងពាក្យបណ្ដឹងចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៧ របស់ឈ្មោះ X

**<u>យោង</u>**៖-មាត្រា **១០១ កថាខណ្ឌទី ៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ **១៩៧៩** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៧

[9] ដោយសារតែឯកសារនេះ ជាឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ដូច្នេះ ការបង្កើតត្រូវស្របតាមមាត្រា ១០១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប្រសិនបើមើលតាម កថាខណ្ឌ និង មាត្រាដដែលគឺ មានកំណត់ថា "ត្រូវមានសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារ នៅក្នុងពាក្យបណ្ដឹង និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង និង អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹងជាអាទិ៍"។ ច្បាប់របស់ប្រទេសជប៉ុន ឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង គឺហៅថា ឯកសារចម្លើយ។

សេចក្តីដូចមានកំណត់ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឈ្មោះ X បានដាក់ពាក្យបណ្តឹងមកសាលាដំបូងរាជធានីភ្នំពេញ ដោយទាមទារឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារ ៖

**ទី១** ចុងចម្លើយ "Y" ត្រូវធ្វើនីតិវិធីលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិដី B ទាំងមូលដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០០១០ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១០ មានទំហំ ៦០០ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ១ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ រវាង X និង Y ដោយមូលហេតុរំលាយកិច្ចសន្យាលក់-ទិញ ចុះថ្ងៃទី ០១ ខែឧសភា ឆ្នាំ ២០១៧ មកឲ្យដើមចោទ"x" ដោយដើមចោទ ត្រូវប្រគល់ប្រាក់ចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ឲ្យចុងចម្លើយ

**ទី២** បង្គាប់ឲ្យចុងចម្លើយប្រគល់ដីដែលមានអត្តសញ្ញាណខាងលើមកឲ្យដើមចោទ

**ទី៣** ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ

**ទី៤** ប្រកាសអនុវត្តជាបណ្តោះអាសន្ន

នៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ខ្ញុំបានទទួលពាក្យបណ្តឹងនេះ តាមរយៈការបញ្ជូនរបស់មន្ត្រីអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ហេតុនេះ ខ្ញុំសុំឆ្លើយតបចំពោះពាក្យបណ្តឹងនេះ ដូចខាងក្រោម ៖

## ក-ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

(១) ច្រានចោលការទាមទារទាំងអស់របស់ដើមចោទ

(២) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ

## ខ-ការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុដែលជាមូលហេតុនៃការទាមទារ

១.ទទួលស្គាល់អង្គហេតុខ.១ ខ.២ និងខ.៣។

២.មិនដឹងអំពីអង្គហេតុ ខ.៤ ។ ចុងចម្លើយមិនបានទទួលលិខិតដាស់តឿនឡើយ។

៤.បដិសេធចំពោះអង្គហេតុ ខ.៥ ។ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ចុងចម្លើយបានបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះចំនួន៧ម៉ឺនដុល្លារក្នុងរឿងក្តីនេះ (ត.១ ៖ វិក្កយបត្រ)។

៥.មិនដឹងអំពីមូលហេតុនៃការទាមទារ ៥។ ចុងចម្លើយមិនបានទទួលលិខិតជូនដំណឹងអំពីការរំលាយ ឡើយ។

៦.មានវិវាទចំពោះអង្គហេតុ ខ.៦។

## គ-អង្គហេតុតវ៉ា ជាអាទិ៍

នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ចុងចម្លើយបានបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះចំនួន ៧ម៉ឺនដុល្លារក្នុងរឿងក្តីនេះ ឲ្យទៅZដែលជាប្រពន្ធរបស់ដើមចោទX ។

ស្តីពីសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា គឺចុងចម្លើយ Y បដិសេធក្នុងការប្រគល់ដីនៃរឿងក្តីនេះ រហូតដល់ពេល ដើមចោទ X ប្រគល់ប្រាក់កក់ ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក ទើបចុងចម្លើយ Y អាចធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីនៃរឿងក្តីនេះ។[10]

## ឃ-ភស្តុតាង

ទម្រង់បែបបទនៃការផ្ទេរប្រាក់របស់ធនាគារកម្ពុជាសាធារណៈ:

## ង-សេចក្តីសន្និដ្ឋាន

ផ្អែកតាមមូលដ្ឋានខាងលើនេះ ការទាមទាររបស់ដើមចោទមិនត្រឹមត្រូវ។

សូម **លោកចៅក្រម** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម **លោកចៅក្រម** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីនាងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៧

**អ្នកតំណាងដោយអាណត្តិ**

B

ឯកសារភ្ជាប់

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-ឯកសារចម្លងនៃឯកសារចម្លើយ "ចំនួន ០២ ច្បាប់"

---

10 ចុងចម្លើយ Y អាចធ្វើការបដិសេធក្នុងការប្រគល់ដីនៃរឿងក្តីនេះ និងអាចធ្វើការបដិសេធក្នុងការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិផងដែរ (ក្រមរដ្ឋប្បវេណី មាត្រា ៥១១ កថាខណ្ឌទី២)។

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

<u>គម្រូឯកសារត្រៀមលើកទី១</u>
<u>របស់ដើមចោទសម្រាប់ករណីសិក្សាទី១</u>

## <u>ឯកសារត្រៀមលើកទី១របស់ដើមចោទ</u>

**ដើមចោទ** ៖ ឈ្មោះ X អាយុ ៥០ ឆ្នាំ មុខរបរពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៩៦៦៨៨៩ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ០២ ផ្លូវលេខ ១៧៩ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "ដើមចោទ" ៖ ខ្ញុំ P ជាមេធាវីនៃក្រុមហ៊ុនមេធាវី................. ដែលមានអាសយដ្ឋានស្ថិតនៅ..................... មហាវិថី................. សង្កាត់........... ខណ្ឌ............. រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ ......................។

ទីកន្លែងបញ្ជូន ៖ ក្រុមហ៊ុនមេធាវី....................

**ចុងចម្លើយ** ៖ ឈ្មោះ Y អាយុ ៦០ ឆ្នាំ មុខរបរពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៩៦៦៨៨៦ ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១៩ ផ្លូវលេខ ៣៨៩ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

**អ្នកតំណាងដោយអាណត្តិ** "ចុងចម្លើយ" ៖ នាងខ្ញុំ B ជាមេធាវីនៃការិយាល័យមេធាវី ................... ដែលមានអាសយដ្ឋានស្ថិតនៅ................... សង្កាត់............. ខណ្ឌ............ រាជធានីភ្នំពេញ ដោយមានលេខទូរស័ព្ទ........................។

ទីកន្លែងបញ្ជូន ៖ ការិយាល័យមេធាវី.................................

## <u>សូមគោរពចូលមក</u>

## លោក W ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**<u>កម្មវត្ថុ</u>**៖សំណើសុំដាក់**ឯកសារត្រៀមលើកទី១របស់ដើមចោទ**ដើម្បីឆ្លើយតបចំពោះឯកសារចម្លើយរបស់ចុងចម្លើយចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ របស់ឈ្មោះ Y

**<u>យោង</u>**៖-មាត្រា **១០១ កថាខណ្ឌទី ៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ **១៩៧៩** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៧

សេចក្ដីដូចមានកំណត់ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឈ្មោះ Y បានដាក់ឯកសារចម្លើយមកសាលាដំបូងរាជធានីភ្នំពេញ។ នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ខ្ញុំបានទទួលឯកសារចម្លើយ

នេះ តាមរយៈការបញ្ជូនរបស់មន្ត្រីអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ ហេតុនេះ ខ្ញុំសុំឆ្លើយតបចំពោះឯកសារចម្លើយនេះ ដូចខាងក្រោម ៖

## ក-ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះឯកសារចម្លើយ

នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ ដើមចោទបានប្រគល់លិខិតដាស់តឿន ដោយផ្ទាល់ដៃឲ្យទៅចុងចម្លើយនៅផ្ទះរបស់ចុងចម្លើយ ហើយនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ដើមចោទបានប្រគល់លិខិតជូនដំណឹងអំពីការរំលាយ ដោយផ្ទាល់ដៃឲ្យទៅចុងចម្លើយនៅផ្ទះរបស់ចុងចម្លើយ។

ដូចនេះ ការបង្ហាញឆន្ទៈរំលាយ និង ការដាស់តឿន ពិតជាមានភាពច្បាស់លាស់ថាបានទៅដល់ចុងចម្លើយ។

## ១-ការអះអាងរបស់ដើមចោទ

ចុងចម្លើយបានអះអាងថា បានសងប្រាក់ថ្លៃលក់ទិញដែលនៅខ្វះចំនួន៧ម៉ឺនដុល្លារទៅឲ្យស្ត្រីម្នាក់ឈ្មោះZដែលត្រូវជាប្រពន្ធរបស់ដើមចោទ (ភ.៥ ៖ សំបុត្រអាពាហ៍ពិពាហ៍) ដូចនេះការអះអាងអំពីការសងរបស់ចុងចម្លើយ ជាព័ត៌មានមិនពិត។ ម្យ៉ាងវិញទៀត បើទោះបីជាចុងចម្លើយបានប្រគល់ប្រាក់ចំនួន៧ម៉ឺនដុល្លារឲ្យទៅស្ត្រីដែលឈ្មោះ Z ពិតប្រាកដមែនក៏ដោយក៏Zជាបុគ្គលដែលមិនជាប់ពាក់ព័ន្ធនៅក្នុងរឿងក្ដីនេះទាល់តែសោះ ហេតុនេះហើយ ការសងនេះ មិនត្រូវទៅនឹងការសងនៃកិច្ចសន្យាលក់ទិញក្នុងរឿងក្ដីនេះឡើយ។

សូម **លោកចៅក្រម** សម្រេចតាមការស្នើសុំ ដោយក្ដីអនុគ្រោះ។

សូម **លោកចៅក្រម** ទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៧

**អ្នកតំណាងដោយអាណត្តិ**

P

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

គម្រូសាលក្រមសម្រាប់ករណីសិក្សាទី១

សាលាដំបូងរាជធានីភ្នំពេញ

## សាលក្រម

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីលេខ ១៩៧៩ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៧

សាលក្រមលេខ ១២៣ "ង" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧

-បានឃើញច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី ១៦-០៧-២០១៤

-បានឃើញមាត្រា **៧៥**, មាត្រា **១៨២** និងមាត្រា **១៨៩** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃ**ទី០៧ ខែធ្នូ ឆ្នាំ២០១៧** និងបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ជាសាធារណៈ នៅថ្ងៃ**ទី០៧ ខែធ្នូ ឆ្នាំ២០១៧** ដោយមានសមាសភាព ៖

## ចៅក្រមជំនុំជម្រះ

លោក J ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជី

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ** ៖ ឈ្មោះ X អាយុ ៥០ ឆ្នាំ ភេទស្រី សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១ ភូមិ២ សង្កាត់៣ ខណ្ឌ៤ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "ដើមចោទ" ៖ លោកមេធាវី P

**ចុងចម្លើយ** ៖ឈ្មោះ Y អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មាអាសយដ្ឋាន ស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "ចុងចម្លើយ" ៖ លោកមេធាវី D

## អង្គហេតុ និងការអះអាងរបស់គូភាគី

ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១.

ខ. អង្គហេតុ និងចំណុចវិវាទ

ខ.១ ការសង្ខេបរឿងក្ដី

កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤

**ខ.២ អង្គហេតុដែលគ្មានវិវាទ**

ខ.២.១.ការលក់ទិញ

ខ.២.២.ការប្រគល់ប្រាក់កក់

**ខ.៣ ចំណុចវិវាទ**

ខ.៣.១. អត្ថិភាព ឬនត្ថិភាពនៃការដាស់តឿន?

ខ.៣.២. អត្ថិភាព ឬនត្ថិភាពនៃការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា?

ខ.៣.៣. អត្ថិភាព ឬនត្ថិភាពនៃការសង?

**ខ.៤. ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ**

**ខ.៤.១. ចំណុចវិវាទទី១**

**-ការអះអាងរបស់ដើមចោទ X**

ដើមចោទបានប្រកបអាជីវកម្ម

**-ការអះអាងរបស់ចុងចម្លើយ Y**

ចុងចម្លើយអះអាងថា

**ខ.៤.២. ចំណុចវិវាទទី២**

**-ការអះអាងរបស់ចុងចម្លើយ Y**

ដើមចោទបាន

**-ការអះអាងរបស់ដើមចោទ X**

ខ្ញុំជាធម្មតា

**ខ.៤.៣. ចំណុចវិវាទទី៣**

**-ការអះអាងរបស់ចុងចម្លើយ Y**

ខ្ញុំគិតថា

**-ការអះអាងរបស់ដើមចោទ X**

ខ្ញុំមិន

## សំអាងហេតុ

**ក. ស្តីពីចំណុចវិវាទទី១**

ក.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់

ករណីរឿងក្តីនេះ

**ក.២. ការវិនិច្ឆ័យអំពីចំណុចវិវាទ**

ករណីនេះ

**ខ. ស្តីពីចំណុចវិវាទទី២**

**ខ.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

ករណីនេះ

**ខ.២.ការវិនិច្ឆ័យអំពីចំណុចវិវាទ**

ករណីនេះ

**គ. ស្តីពីចំណុចវិវាទទី៣**

**គ.១. អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់**

២ (ពីរ) សប្តាហ៍មុន

**គ.២.ការវិនិច្ឆ័យអំពីចំណុចវិវាទ**

សាក្សី B បានអះអាងថា

**ឃ.សេចក្តីសន្និដ្ឋាន**

ដើមចោទទាមទារឲ្យប្រកាសអនុវត្តបណ្តោះអាសន្ន តុលាការអាចទទួលស្គាល់បាន (មាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដោយហេតុថា ទី១ ចរិកលក្ខណៈនៃការទាមទារចម្បងនិងបន្ទាប់បន្សំរបស់ដើមចោទ ជាសិទ្ធិលើទ្រព្យសម្បត្តិ ទី២ ការទាមទារនេះមានលក្ខណៈច្បាស់លាស់ និងមានភស្តុតាងគ្រាប់គ្រាន់ ហើយចុងចម្លើយទទួលស្គាល់ការខូចខាតដោយគ្រាន់តែស្នើសុំទូទាត់កំហុស និងកាត់បន្ថយចំណាយដោយមូលហេតុរបស់ដើមចោទ និងទី៣ ទោះបីជាតុលាការជាន់ខ្ពស់សម្រេចផ្ទុយពីនេះ ក៏សិទ្ធិនេះអាចធ្វើបដិទាន បានចំពោះការទាមទារចំណុចទី២ ប៉ុន្តែចំណុចទី១ មិនបាននោះទេ។

រឿងក្តីលុបការចុះបញ្ជីនេះ ប្រាក់ប្រដាប់ក្តី គប្បីឲ្យដើមចោទ និងចុងចម្លើយទទួលបន្ទុកម្នាក់ៗមួយផ្នែក (មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដោយហេតុថាដើមចោទ ក៏មានកំហុស ហើយចុងចម្លើយក៏មានកំហុស ហេតុនេះ ចំនួនប្រាក់ប្រដាប់ក្តីគប្បីសមាមាត្រនឹងកំហុសរបស់ភាគីនីមួយៗ។

ជាសរុប តុលាការនឹងសម្រេចរឿងក្តីនេះ ដូចខាងក្រោម ៖

## សេចក្តីសម្រេចបញ្ចប់

(១) ចុងចម្លើយ "Y" ត្រូវធ្វើនីតិវិធីលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិដី L ទាំងមូល ដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០០១០ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១០ មានទំហំ ៦០០ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិ ១ សង្កាត់ផ្សារថ្មី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ រវាង X និង Y ដោយមូលហេតុរំលាយកិច្ចសន្យាលក់-ទិញ ចុះថ្ងៃទី ០១ ខែឧសភា ឆ្នាំ ២០១៧ មកឲ្យដើមចោទ"X"

(២) បង្គាប់ឲ្យចុងចម្លើយប្រគល់ដីដែលមានអត្តសញ្ញាណខាងលើមកឲ្យដើមចោទ

(៣) ច្រានចោលការទាមទារក្រៅពីនេះរបស់ដើមចោទ X

(៤) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ Y

(៥) ប្រកាសអនុវត្តជាបណ្តោះអាសន្នបានចំពោះចំណុចទី២។

សាលក្រមនេះប្រកាសជាសាធារណៈនៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៧ ចំពោះមុខភាគី និងអ្នកតំណាងដោយអាណត្តិរបស់ភាគី។ ទុកសិទ្ធិឲ្យភាគីប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលលិខិតសាលក្រមនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៧

**ចៅក្រម**